ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការហាមប្រើប្រាស់ គ្រាប់មីនគ្រប់ប្រភេទ ប្រឆាំងមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

# ស្តីពី

# ការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

២៤៤៥

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.-

ច្បាប់នេះមានគោលដៅហាមឃាត់ការប្រើប្រាស់ ការផលិត ការកាន់កាប់ ការជួញដូរ ការនាំចេញ និងការនាំចូលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ។

### មាត្រា ២.-

គ្រាប់មីនប្រឆាំងមនុស្ស គឺគ្រាប់មីនទាំងឡាយដែលធ្វើឡើងដើម្បីឱ្យផ្ទុះនៅពេលមានវត្តមានមនុស្សក្នុងទីជិត ឬឆ្ងាយ ឬនៅពេលមនុស្សទៅប៉ះបណ្តាលឱ្យមនុស្សម្នាក់ ឬច្រើននាក់រងរបួស ពិការ ឬស្លាប់ ។

គ្រាប់មីនគឺជាយុទ្ធោបករណ៍ដែលគេយកទៅកប់ក្នុងដី ឬដាក់លើផ្ទៃដី ឬនៅលើទីដទៃទៀត ហើយដែលផ្ទុះនៅពេលមានវត្តមានឆ្ងាយ ឬជិតនៃមនុស្ស សត្វ ឧបករណ៍ ឬគ្រឿងយន្តទាំងឡាយ ឬផ្ទុះនៅពេលមានមនុស្ស សត្វ ឧបករណ៍ ឬគ្រឿងយន្តទៅប៉ះ ។

### មាត្រា ៣.-

ជនស៊ីវិល ភ្នាក់ងាររាជការទាំងអស់និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទជាពិសេស កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងកម្លាំងនគរបាលជាតិ ត្រូវហាមឃាត់ប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ក្នុងគ្រប់កាលៈទេសៈ លើកលែងតែក្នុងករណីប្រើប្រាស់ ដើម្បីធ្វើការបណ្តុះបណ្តាលហ្វឹកហាត់បោសសំអាតមីន ។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

### មាត្រា ៤.-

ការត្រួតពិនិត្យគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ជាសមត្ថកិច្ចរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

មាត្រា ៥.-

ក្រៅពីភារកិច្ចដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ភារកិច្ចបន្ថែមរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាមាន :

-ចូលរួមសហការធ្វើអធិការកិច្ចជាមួយក្រសួងឬស្ថាប័នពាក់ព័ន្ធនៅគ្រប់ទីកន្លែងដែលគេសង្ស័យថាមានការរំលោភលើការហាមឃាត់ តាមការកំណត់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ។

-សំរេចកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្សទាំងអស់ ដែលនៅមាននិងរកឃើញ ។

-សំរេចកំទេចចោលគ្រាប់មីនគ្រប់ប្រភេទក្រៅពីគ្រាប់មីនប្រឆាំងមនុស្សនិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងអស់ដែលនៅមាននិងរកឃើញដោយពុំមានការគ្រប់គ្រងនិងថែរក្សាទុកដោយអាជ្ញាធរមានសមត្ថកិច្ច ។

-ធ្វើសហប្រតិបត្តិការជាមួយអង្គការបរទេសដើម្បីទប់ស្កាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ។

-ទទួលរបាយការណ៍ពីអង្គភាពនានា ស្តីពីការប្រើប្រាស់ ដោយគិតទាំងការកាន់កាប់ ការផ្ទេរ ការជួញដូរ ការនាំចេញ ការនាំចូលគ្រាប់មីនគ្រប់ប្រភេទ ហើយរាយការណ៍ជូនរដ្ឋាភិបាល ។

-ទទួលភារកិច្ចធ្វើការគ្រប់គ្រង ត្រួតពិនិត្យ ឬសម្របសម្រួលការងារដោះមីននិងកំទេចគ្រឿងផ្ទុះគ្រប់ប្រភេទនៃអង្គការក្រៅរដ្ឋាភិបាលទាំងឡាយដែលកំពុងឬដែលនឹងមកបំពេញកិច្ចប្រតិបត្តិការបោសសំអាតមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

-ធ្វើសហការជាមួយស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតូបករណ៍អន្តរជាតិទាំងឡាយក្នុងការបំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងបញ្ហាមីនប្រឆាំងមនុស្សគ្រប់ប្រភេទ ។

ក្រសួងឬស្ថាប័នដែលត្រូវចូលរួមធ្វើអធិការកិច្ចនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

### មាត្រា ៦.-

ជនណាកាន់កាប់ ថែរក្សាទុក ដោយចេតនានូវគ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែដល់មួយឆ្នាំ និងពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន (៥.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

### មាត្រា ៧.-

ជនណាប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល ដោយមិនទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ ចំពោះបច្ច័យនៃបទល្មើសដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិត និងរូបរាងកាយមនុស្ស និងសំណង់វត្ថុប្បវេណីផ្សេងៗទៀតឡើយ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

### មាត្រា ៨.-

ជនណាផលិត ផ្ញើផ្ញើរ នាំចូល ឬនាំចេញ គ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំដល់ដប់ឆ្នាំ និងពិន័យជាប្រាក់ពីដប់លាន(១០.០០០.០០០)រៀល ដល់ម្ភៃលាន(២០.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

គ្រាប់មីនទាំងឡាយដែលបានលើកឡើងក្នុងមាត្រា ៦ មាត្រា ៧ និងមាត្រា ៨ ត្រូវរឹបអូស និងបំផ្លាញចោល ។

## មាត្រា ៩.-

បើជនល្មើសជាភ្នាក់ងារ ឬមន្ត្រីនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ឬជាភ្នាក់ងារ ឬជាមន្ត្រីនៃអង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសកម្មភាពប្រហាក់ប្រហែលនឹងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាដែរនោះ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៦ មាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះជា អតិបរមា ដោយឥតមានការសំរាលទោសឡើយ ។

# ជំពូកទី ៤
# អន្តរប្បញ្ញត្តិ

## មាត្រា ១០.-

ជនណា ឬក្រសួងណា ឬស្ថាប័នណាដែលបានកាន់កាប់គ្រាប់មីនប្រឆាំងមនុស្សប្រភេទណាក៏ដោយ ត្រូវធ្វើរបាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដែលមានកាតព្វកិច្ច ធ្វើសេចក្តីរាយការណ៍ជូនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា បញ្ជាក់អំពីប្រភេទ ចំនួននិងពត៌មានពិស្តារផ្សេងៗពាក់ព័ន្ធនឹងគ្រាប់មីនដែលខ្លួនកំពុងកាន់កាប់ ថែរក្សាទុក ក្នុងរយៈពេលកៅសិបថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃដែលច្បាប់នេះ ចូលជាធរមានប្បញ្ញត្តិ ។

## មាត្រា ១១.-

មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាត្រូវកំទេចគ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទទាំងនោះ តាមការកំណត់ដូចមានចែងក្នុងមាត្រា ១០ ឱ្យអស់ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រួចហើយត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាមីនប្រឆាំងមនុស្ស ហើយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ២ ។

ភ្នំពេញ,ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៩

**ប្រធានរដ្ឋសភា**

**នរោត្តម រណឫទ្ធិ**